**BRIEFING NOTES**

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

២៥ សីហា ២០១៧

**អ្នកនាំពាក្យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស៖ អ្នកស្រី លីហ្ស ស្រូសហ្សែលល័**

**ទីតាំង៖ ទីក្រុងហ្សឺណែវ**

**កម្មវត្ថុ៖ (១) យេម៉ែន (២) កម្ពុជា (៣) ក្វាតេម៉ាឡា**

**(១) យេម៉ែន** ……………………………………………………………………………………
……………………………………………………………………………………………………
……………………………………………………………………………………………………

**(២) ប្រទេសកម្ពុជា**

យើងមានកង្វល់អំពីការចាត់ជាបន្តបន្ទាប់យ៉ាងឆាប់រហ័សនូវវិធានការរដ្ឋមន្ត្រី និងរដ្ឋបាល ដែលបាននាំឲ្យមានការផ្អាកកម្មវិធី និងអាជ្ញាប័ណ្ណវិទ្យុ បានគំរាមបិទកាសែតភាសាអង់គ្លេសដ៏ធំមួយ និងបិទអង្គការមិនមែនរដ្ឋាភិបាលបរទេសមួយ។ នៅមុនការបោះឆ្នោតសកលនៅឆ្នាំក្រោយនេះ យើងអំពាវនាវដល់រដ្ឋាភិបាល សូមធានាឲ្យបានពេញលេញនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងសេរីភាពខាងសារព័ត៌មាន។

អង្គការមិនមែនរដ្ឋាភិបាលបរទេសមួយ ដែលមានឈ្មោះថា វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) ត្រូវបានបិទដោយបទបញ្ជារដ្ឋមន្ត្រីនៅថ្ងៃទី២៣ ខែសីហាឆ្នាំ ២០១៧ ការបិទដូចនេះគឺជាលើកដំបូងហើយ ដែលបានធ្វើឡើងដោយយោងតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ២០១៥។ បុគ្គលិកអន្តរជាតិរបស់អង្គការនេះ ត្រូវបានបញ្ជាឲ្យចាកចេញពីប្រទេសក្នុងរយៈពេលប្រាំពីរថ្ងៃ។ អង្គការនេះបានធ្វើការលើវិស័យបោះឆ្នោតនិងជាមួយភាគីនានានៅទូទាំងវិសាលគមនយោបាយ។ អង្គការកម្ពុជាចំនួនបី ដែលធ្វើការលើវិស័យសិទ្ធិមនុស្សនិងការបោះឆ្នោត ក៏ត្រូវបានទទួលរងនូវការស៊ើបអង្កេតគោលដៅពន្ធដារកាលពីដើមខែនេះផងដែរ។ យើងមានកង្វល់ថា NDI ត្រូវបានបិទដោយមិនមានដំណើរការនីតិវិធីត្រឹមត្រូវ ហើយមានការព្រួយបារម្ភអំពីការធ្លាក់ចុះជាទូទៅនៃបរិយាកាសសម្រាប់អ្នកការពារសិទ្ធិមនុស្សនិងសង្គមស៊ីវិលនៅប្រទេសកម្ពុជា។

ដូចគ្នានេះដែរ នៅសប្តាហ៍នេះ រដ្ឋាភិបាលបានដកហូតអាជ្ញាប័ណ្ណសម្រាប់រលកធាតុអាកាសផ្សាយ (ប្រេកង់) នៃវិទ្យុមួយចំនួន ដែល ធ្វើឲ្យរារាំងដល់កម្មវិធីចាក់ផ្សាយតាមរលកធាតុអាកាសរបស់អង្គការជាតិឯករាជ្យខាងសិទ្ធិ

មនុស្សនិងប្រព័ន្ធផ្សព្វផ្សាយ ស្ថានីយ៍វិទ្យុអាស៊ីសេរី (RFA) និងវិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) ដែលទទួលមូលនីធិពីសហរដ្ឋអាមេរិក និងគណបក្សប្រឆាំងដ៏ធំមួយ។ កាសែតធំមួយ ក្នុងចំណោមកាសែតឯករាជ្យធំៗដទៃទៀត ជាអង់គ្លេស គឺកាសែតឌឺខេមបូឌាដេលី ត្រូវបានគេទុកពេលឲ្យរហូតដល់ថ្ងៃទី៤ ខែកញ្ញា ដើម្បីធ្វើការទូទាត់បំណុលពន្ធដែលបានអះអាងគឺចំនួន៦,៣ លានដុល្លារ បើពុំនោះទេ ត្រូវបិទ។ កាសែតនេះ បានអំពាវនាវឲ្យមានការធ្វើសវនកម្មពន្ធដារប្រកបដោយតម្លាភាព និងសុំសិទ្ធិប្តឹងឧទ្ធរណ៍ ប៉ុន្តែសំណូមពររបស់កាសែតនេះ មិនត្រូវបានអើពើឡើយ។

យើងអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា សូមធានាឲ្យមានដំណើរការនីតិវិធីត្រឹមត្រូវ ចំពោះគ្រប់វិធានការដែលបានចាត់ឡើង រាប់ទាំង សិទ្ធិប្តឹងឧទ្ធរណ៍ និងសូមឲ្យគោរពសិទ្ធិសេរីភាពខាងសមាគម និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។

**(៣) ក្វាតេម៉ាឡា** ……………………………………………………………………………………………………………………………………………………………………………………………………………………………………………………………………

# ចប់

សម្រាប់ព័ត៌មានបន្ថែមនិង***ការសាកសួរព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ*** សូមទាក់ទងមក លីហ្ស ស្រូសហ្សែលល៍ តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៤៦៦ ឬតាមអ៊ីមែល៖ *ethrossell@ohchr.org)* ឬ
លោក រ៉ូផើត ខូលវីល (Rupert Colville) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៧ ៦៧ ឬតាមអ៊ីមែល៖ *rcolville@ohchr.org)*

**សូមចែកនិងចែករំលែក - ទ្វីតធឺរ: @UNHumanRights និងហ្វេសប៊ុក: unitednationshumanrights**

តើមានកង្វល់នានាអំពីពិភពលោកដែលយើងរស់នៅមែនទេ? ដូច្នេះ **សូមក្រោកឈរដើម្បីសិទ្ធិរបស់នរណាម្នាក់នៅថ្ងៃនេះ។** # Standup4humanrights ហើយចូលទៅកាន់គេហទំព័រ http://www.standup4humanrights.org